ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៛៥

សាលាដំបូងខេត្ត

-ក្រចេះ-

៣៛៥

សាលក្រមលេខ: ៦២ ក

ចុះថ្ងៃទី ១១.០៩.២០០៩

សំណុំរឿងលេខ:១៥០

ចុះថ្ងៃទី ១៧.០៩.០៧

## តាងនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តក្រចេះ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៨.០២.៩៣។

បានបើកសវនាការជាសាធារណៈនៅនាទីសាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ដោយក្រុមប្រឹក្សាជំនុំជំរះមានសមាសភាពដូចតទៅ:

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាសមាជិកក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាសមាជិកក្រុមប្រឹក្សាជំនុំជំរះ

-តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តក្រចេះ

- ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ

ដើម្បីជំនុំជំរះលើឈ្មោះ [redacted] សុផា ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា ទីលំនៅកំណើតនៅភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ លំនៅសព្វថ្ងៃនៅភូ[redacted] ខេត្តក្រចេះ សាសនាព្រះពុទ្ធ របររកស៊ីកម្មករ ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន៧នាក់ ទោសពីមុនគ្មាន។ ចាប់ខ្លួនពីថ្ងៃទី ១៦.៩.០៧ និង ឃុំខ្លួន កាលពីថ្ងៃទី ១៧.៩.០៧។ មានលោក [redacted] រិម ជាមេធាវីការពារ។

ត្រូវជាប់ចោទពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី ១៥.០៩.០៧។

បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធារីហៅណាក់ ភេទស្រី អាយុ១៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិតាម៉ៅ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ២៧ ព.ស ចុះថ្ងៃទី ២១.០៧.០៨ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តក្រចេះ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខៈ ៣៦ ចុះថ្ងៃទី ១៨.០៧.០៨ របស់ចៅក្រមស៊ើបសួរ ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជំរះលេខ ០១ ចុះថ្ងៃទី ០២.០១.០៨ របស់សាលាដំបូងខេត្តក្រចេះ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៧ ឈ្មោះនាង [redacted] ធារីរ៉ា ឈ្មោះ [redacted] សុផា ជាឪពុកចុង បានទៅធ្វើជាកម្មករដាំកូនឈើអោយក្រុមហ៊ុនចិននៅឃុំអូរគ្រៀងក៏បានដេករួមរ៉ែក្សជាមួយគ្នាបន្តបន្ទាប់ច្រើនលើក លុះដល់ថ្ងៃទី ១៥.០៥.០៧ ជនជាប់ចោទបានហៅជនរងគ្រោះឱ្យទៅដេកជាមួយ តែជនរងគ្រោះមិនព្រមទៅ ក៏ជនរងគ្រោះប្តឹងសមត្ថកិច្ចចាប់ឃាត់ខ្លួនជនជាប់ចោទតែម្តង ។

## សាពេលសមខនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុផា បានឆ្លើយថាៈ កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៧ ខ្ញុំ និង កូនចុងរបស់ខ្ញុំឈ្មោះ [redacted] ធារីបានទៅធ្វើជាកម្មករដាំកូនឈើអោយក្រុមហ៊ុនចិននៅឃុំអូរគ្រៀង ហើយនៅក្នុងរយៈពេលដាំកូនឈើនោះ ខ្ញុំមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ ដោយខ្ញុំដេកនៅកន្លែងប្រុសៗ ឯកូនចុងរបស់ខ្ញុំ បានឱ្យទៅដេកទៅជាមួយបងស្រីខ្ញុំឈ្មោះ [redacted] សុផាត លុះដល់ថ្ងៃទី១៥.០៥.០៧ ខ្ញុំយកនាឡិកាដៃបានប្រាក់២០.០០០៛ ក៏ហៅឱ្យកូនស្រីយកលុយត្រឡប់ទៅផ្ទះវិញ ស្រាប់តែបងស្រីខ្ញុំឈ្មោះ [redacted] សុផាត មកឈ្លោះប្រកែកជាមួយខ្ញុំហើយនាំ [redacted] ធារីទៅប្តឹងសមត្ថកិច្ចចាប់ខ្លួនខ្ញុំតែម្តង ។

-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ [redacted] ធារីបានឆ្លើយថាៈ ខ្ញុំបានទៅធ្វើការឱ្យក្រុមហ៊ុនចិនជាមួយឪពុកចុងខ្ញុំឈ្មោះ [redacted] សុផា និង អ៊ុំខ្ញុំឈ្មោះ [redacted] សុផាត រហូតដល់ពេលដូរក្រុមហ៊ុន ទើបប៉ាខ្ញុំបានហៅខ្ញុំឱ្យទៅដេកជាមួយពួកគាត់ ដោយមកពីអ្នកធ្វើការឱ្យក្រុមហ៊ុនមានគ្នាច្រើនច្របូកច្របល់ពេក តែខ្ញុំពុំព្រមទៅទេហើយអ៊ុំខ្ញុំក៏ឈ្លោះជាមួយប៉ាខ្ញុំ ខ្ញុំនិងប៉ាខ្ញុំពុំដែលទំនាក់ទំនងរួមរ៉ែក្សនឹងគ្នាទេ ខ្ញុំឆ្លើយពីមុនដោយខ្ញុំខឹងនឹងប៉ារករឿងអោយឈប់ធ្វើការ នៅថ្ងៃកើតហេតុអ៊ុំខ្ញុំឈ្លោះគ្នាជាមួយប៉ាខ្ញុំក៏គាត់ឱ្យខ្ញុំចោទប៉ាខ្ញុំឱ្យធ្ងន់ៗ ខ្ញុំមិនបានប្តឹងពីប៉ាខ្ញុំទេ គឺអ៊ុំខ្ញុំគាត់ជាអ្នកឆ្លើយឱ្យសន្តិសុខកត់ត្រាបណ្តើរ ខ្ញុំឈប់ប្តឹងពីប៉ាខ្ញុំហើយ ។

-តាមចំលើយសាក្សីឈ្មោះ [redacted] សុផាត បានឆ្លើយថាៈ ក្មួយស្រីខ្លួនឈ្មោះ [redacted] ធារី ធ្វើការក្រុមហ៊ុនចិន G.T.W នៅអូរគ្រៀងជាមួយខ្លួន ក្រោយមកឪពុកចុងឈ្មោះ [redacted] សុផា បានទៅហៅឈ្មោះ [redacted] ធារី ជាកូនចុងពីកន្លែងខ្លួនអោយទៅដេកជាមួយដោយយប់នោះភ្លៀងស្រោចខ្លាំង ដល់ព្រឹកឡើងឈ្មោះ [redacted] សុផា ប្រាប់ថា [redacted] ធារី វា

G:\...doc



Scanned by CamScanner

ចុកពោះ ខ្លួនក៏មិនចាប់អារម្មណ៍ទេ លុះយប់ថ្ងៃទី១៣.៩.០៧ ទើបឈ្មោះ [redacted] ធារី ប្រាប់ពីរឿងឪពុកចុងចាប់រំលោភសេពសន្ថវៈ ហើយខ្លួននិងក្មួយក៏មករាយការណ៍ជូនសន្តិសុខរបស់ក្រុមហ៊ុន។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: ជនជាប់ចោទបានបដិសេធ ចំលើយរបស់ខ្លួននៅគ្រប់ដំណាក់កាល តែដោយផ្អែកតាមចំលើយពីកន្លងមកឃើញថាមានការស៊ីសង្វាក់អាចជឿបាន ដូច្នេះតំណាងអយ្យការសុំរក្សាបទចោទប្រកាន់លើជនជាប់ចោទពីបទប៉ុនប៉ងរំលោភសេពសន្ថវៈទុកជាបទការ និងសុំតុលាការសំរេចតាមច្បាប់។

-លោក [redacted] អិម មេធាវីការពារសិទ្ធិអោយជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថា: ជនជាប់ចោទនិងជនរងគ្រោះបានឆ្លើយដូចគ្នាបដិសេធនូវការចោទប្រកាន់ថាពួកខ្លួនមិនបានដេករួមរ័ក្សជាមួយគ្នាឪពុកជាមួយកូនទេ ដូច្នេះបញ្ជាក់ឱ្យឃើញថាការចោទប្រកាន់នេះគ្រាន់តែមានវិមតិសង្ស័យដែលជាប្រយោជន៍ដល់ជនជាប់ចោទប៉ុណ្ណោះ សុំតុលាការពិចារណានិងសំរេចតាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] សុផា បានឆ្លើយជាចុងក្រោយថា: សុំតុលាការដោះលែងខ្ញុំឱ្យបានទៅរកស៊ីចិញ្ចឹមប្រពន្ធកូនវិញ ព្រោះខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-ក្រោយពីបានស្ដាប់ចំលើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចំលើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចំលើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្ដាប់ជនជាប់ចោទឆ្លើយជាចុងក្រោយ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តក្រចេះ**

-យល់ឃើញថា: កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៧ ឈ្មោះនាង [redacted] ធារី និង ឈ្មោះ [redacted] សុផា ជាឪពុកចុង បានទៅធ្វើជាកម្មករដាំកូនឈើអោយក្រុមហ៊ុនចិននៅឃុំអូរគ្រៀង ក៏បានដេករួមរ័ក្សនឹងគ្នាបន្តបន្ទាប់ច្រើនលើក លុះដល់ថ្ងៃទី ១៥.០៩.០៧ ជនជាប់ចោទបានហៅជនរងគ្រោះឱ្យទៅដេកជាមួយ តែជនរងគ្រោះមិនព្រមទៅ ក៏ជនរងគ្រោះប្ដឹងសមត្ថកិច្ចចាប់ឃាត់ខ្លួនជនជាប់ចោទតែម្ដង។

-យល់ឃើញថា: ចំលើយរបស់ជនជាប់ចោទនិងជនរងគ្រោះ ដែលបានឆ្លើយនៅក្នុងនីតិវិធីស៊ើបអង្កេត ក៏ដូចជានៅក្នុងនីតិវិធីស៊ើបសួរ បានឆ្លើយស៊ីសង្វាក់គ្នាថាចាប់ពីខែ៤ឆ្នាំ២០០៧ ក្នុងពេលទៅធ្វើកម្មករដាំឈើឱ្យក្រុមហ៊ុនចិនបានដេករួមរ័ក្សនឹងគ្នាបន្តបន្ទាប់ច្រើនលើក ប៉ុន្តែនៅពេលសវនាការ បានបដិសេធដូចគ្នាថាពួកខ្លួនមិនបានដេករួមរ័ក្សនឹងកូនជាមួយគ្នាទេ ដូច្នេះបញ្ជាក់ឱ្យឃើញថា ចាប់ពីខែ៤ឆ្នាំ២០០៧ ក្នុងពេលទៅដាំឈើឱ្យក្រុមហ៊ុនចិន បើទុកជា



Scanned by CamScanner

ជនជាប់ចោទនិងជនរងគ្រោះបានដេករួមរ័ក្សនឹងគ្នាប្រាកដមែន ក៏ជាការរួមរ័ក្សនឹងគ្នាដោយស្ម័គ្រចិត្ត និងមានការព្រមព្រៀងឯកភាពជាមួយគ្នា គ្មានការគំរាមកំហែងនិងបង្ខិតបង្ខំទេ គឺជាអំពើគ្មានទោស ហើយនៅពេលសវនាការជនជាប់ចោទនិងជនរងគ្រោះថាពួកខ្លួនមិនបានដេករួមរ័ក្សនឹងគ្នានោះក៏ជាអំពើគ្មានទោសដែរ ។

-យល់ឃើញថាៈ តាមចំលើយជនជាប់ចោទឈ្មោះ[redacted] សុផា ថាៈនៅថ្ងៃទី១៥.០៩.០៧ ខ្លួនលក់នាឡិកាដៃបាន២០.០០០៛ ហៅឱ្យកូនស្រីយកត្រឡប់ទៅផ្ទះវិញ ស្រាប់តែបងស្រីឈ្មោះ[redacted] សុផាត មកឈ្លោះប្រកែកជាមួយខ្លួន និងនាំឈ្មោះ[redacted] ធាវី ទៅប្តឹង ហើយជនរងគ្រោះឈ្មោះ [redacted] ធាវី ថានៅថ្ងៃកើតហេតុជនជាប់ចោទបានទៅហៅខ្លួនឱ្យមកដេកជាមួយគាត់តែខ្លួនមិនព្រមទៅ ឃើញថាអំពើរបស់ជនជាប់ចោទដែលបានប្រព្រឹតនៅថ្ងៃទី១៥.០៩.០៧ ដែលជាមូលដ្ឋាននៃការចោទប្រកាន់នេះ ពុំមានធាតុផ្សំគ្រប់គ្រាន់ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈដូចការចោទប្រកាន់ទេ ពីព្រោះជនជាប់ចោទមិនទាន់បានតាំងផ្តើមនូវកំលាំងបង្ខំ ឬ បានប្រើហិង្សាទៅលើរាងកាយជនរងគ្រោះក្នុងបំណងដោយផ្ទាល់ដើម្បីរំលោភសេពសន្ថវៈនោះឡើយ គឺការដែលជនជាប់ចោទគ្រាន់តែបានហៅជនរងគ្រោះនោះជាអំពើត្រៀមបំរុងដែលពុំមានគោលបំណងដោយផ្ទាល់ក្នុងបទចោទប្រកាន់នេះទេ។

-យល់ឃើញថាៈ គ្មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ[redacted] សុផា ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី ១៥.០៩.០៧ ដូចការចោទប្រកាន់ទេ ហើយដើមបណ្តឹងរដ្ឋប្បវេណីជាជនរងគ្រោះឈ្មោះ [redacted] ធាវី ក៏បានសុំដកពាក្យបណ្តឹងឈប់ប្តឹងដែរ ។

**ហេតុដូច្នេះតុលាការខេត្តក្រចេះ**

**វិនិច្ឆ័យសេចក្តី**

១-សំរេចអោយឈ្មោះ [redacted] សុផា ភេទប្រុស អាយុ៣៧ឆ្នាំ រួចខ្លួនពីបទចោទប្រកាន់ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រែស្បូវ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី១៥.៩.០៧ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៩នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង បង្គាប់ឱ្យដោះលែងឈ្មោះនេះចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ភ្លាម ប្រសិនបើឈ្មោះនេះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

២-សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុផា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធាវី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | សមាជិកក្រុមប្រឹក្សា | សមាជិកក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|---|
| ហត្ថលេខានិងត្រា : | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និង ត្រា : |
| [redacted] | [redacted] | [redacted] | [redacted] |

បាន[illegible]
ក្រចេះ ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០០៩
ប្រធានក្រុមប្រឹក្សាជំនុំជំរះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ក្រចេះ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩
ក្រឡាបញ្ជី



Scanned by CamScanner